មជ្ឈមណ្ឌលឯកសារកម្ពុជា

# អង្គជំនុំជម្រះសាលាដំបូង បដិសេធការស្នើសុំស៊ើបអង្កេតចំពោះ ការជ្រៀតជ្រែករបស់រដ្ឋាភិបាលក្នុងសំណុំរឿង០០២

*អែន ហេនខែល ទីប្រឹក្សាច្បាប់របស់មជ្ឈមណ្ឌលឯកសារកម្ពុជា*

*ប្រែសម្រួលដោយ ភួង ប្រណិត*

*២៦ វិច្ឆិកា ២០១២*

កាលពីខែមេសាកន្លងទៅ មេធាវីការពារក្តីរបស់ នួន ជា បានស្នើសុំអង្គជំនុំជម្រះសាលាដំបូងឲ្យបន្តដំណើរនីតិវិធីលើសំណុំរឿង០០២នៅអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា និងស៊ើបអង្កេតលើការចោទប្រកាន់របសសហចៅក្រមស៊ើបអង្កេតអន្តរជាតិបម្រុងលោក កាសស្ព័រ អានសាមេត ដែលមន្ត្រីតុលាការ បានរារាំងលើកិច្ចខិតខំប្រឹងប្រែងក្នុងការស៊ើបអង្កេតសំណុំរឿង០០៣និង០០៤ ។ បើយោងតាមការរាប់ចំនួនរបស់ក្រុមមេធាវីការពារក្តីរបស់ នួន ជា នេះគឺជាសំណើរលិខិតលើកទី៤ ដែលប្រឆាំងនឹងភាពយុត្តិធម៌នៃសំណុំរឿង០០២ ដោយចោទថាមានការលូកដៃជ្រៀតជ្រែកពីខាងរដ្ឋាភិបាលក្នុងកិច្ចការរបស់តុលាការ ។

ក្នុងការដាក់បណ្តឹងជំទាស់របស់ខ្លួន ក្រុមមេធាវីការពារក្តីបានអះអាងចំពោះការលាលែងរបស់ចៅក្រម កាសស្ព័រ អានសាមេត និងការចោទប្រកាន់ពីសាធារណជនគឺជា «ភស្តុតាងរួម» ដែលឥទ្ធិពលរបស់រដ្ឋាភិបាលកម្ពុជានៅក្នុងតុលាការ «ធ្វើឲ្យប៉ះពាល់ដល់បុគ្គលិកថ្នាក់ជាតិគ្រប់រូបរួមមានចៅក្រមអង្គជំនុំជម្រះសាលាដំបូងជាតិ និងប៉ះពាល់ដល់សំណុំរឿងដែលមិនទាន់ជំនុំជម្រះទាំងអស់» ។ ជាងនេះទៅទៀត ក្រុមមេធាវ៉ការពារក្តីបានលើកឡើងថា ការប្រឆាំងរបស់រដ្ឋាភិបាល ដែលរិះគន់មិនសំចៃម៉ាត់ក្នុងការបង្អាក់សំណុំរឿង០០៣ និងសំណុំរឿង០០៤ បានជះឥទ្ធិពលយ៉ាងខ្លាំងដល់សំណុំរឿង០០២ ។ មេធាវីការពារក្តីកំពុងតែគាំទ្រសំណុំរឿងពេលបច្ចុប្បន្ននេះ ខណៈពេលដែលរដ្ឋាភិបាលកំពុងតែជំទាស់មិនឲ្យមានការកាត់ទោសបន្ថែមនៅក្នុងសំណុំរឿង០០៣ និង០០៤ ។ ដូច្នេះការផ្តន្ទាទោសជនជាប់ចោទក្នុងសំណុំរឿង០០២ គឺជៀសមិនផុតពីការធ្វេសប្រហែសនឹងអង្គហេតុដែលបានបង្កើតឡើងនៅក្នុងតុលាការនោះឡើយ ។ ក្រុមមេធាវីការពារក្តី បាននិយាយថា ៖

> ខ្លួននឹងជំទាស់ទៅនឹងការលាក់កំបាំងរឿងប្រឌិត ដែលថាមានតែសំណុំរឿង០០៣ និងសំណុំរឿង០០៤ប៉ុណ្ណោះត្រូវរងការជ្រៀតជ្រែកពីរដ្ឋាភិបាល ។ ខណៈពេលដែល ការជ្រៀតជ្រែករបស់រដ្ឋាភិបាលក្នុងសំណុំរឿងទាំងនោះ (បានរារាំងសែនៗលើដំណើរការគ្រប់ជំហាននោះ) មានលក្ខណៈច្បាស់លាស់ជាក់ស្តែងភាពឥតអៀនខ្មាស់នេះមិនបានលាក់កំបាំងនូវកលល្បិច ដែលប្រែ

ដោយមនុស្សដដែលដើម្បីធានាឲ្យមានការផ្តន្ទាទោសក្នុងសំណុំរឿង ០០២ ហើយការពារមន្ត្រីរដ្ឋាភិបាលពីភាពអាម៉ាស់ ឬការទទួលរងភាពអាម៉ាស់នោះឡើយ ។

ក្រុមមេធាវីការពារក្តីបានចោទប្រកាន់ថា ការជ្រៀតជ្រែករបស់រដ្ឋាភិបាលបានរារាំងកិច្ចខិតខំប្រឹងប្រែងម្តងហើយម្តងទៀតរបស់ខ្លួនដើម្បីឲ្យតុលាការកោះហៅសម្តេចសីហនុ (ដែលបច្ចុប្បន្នបានចូលទីវង្គត់) និងមន្ត្រីរដ្ឋាភិបាល៦រូបមកផ្តល់សក្ខីកម្មជាសក្សី ។

ជាការឆ្លើយតប ព្រះរាជអាជ្ញាបានលើកឡើងថា សំណើរបស់ក្រុមមេធាវីការពារក្តី "គឺបានខកខានក្នុងការបង្ហាញពីការរំលោភបំពានណាមួយនៃសិទ្ធិរបស់ជនជាប់ចោទ នៅក្នុងដំណើរការជំនុំជម្រះក្តីក្នុងសំណុំរឿង០០២ ហើយផ្ទុយទៅវិញ សំណើនោះមានមូលដ្ឋានផ្អែកលើការសន្និដ្ឋាន កើតចេញពីសំណុំរឿង០០៣ និង០០៤ប៉ុណ្ណោះ" ។ ជាងនេះទៅទៀត ព្រះរាជអាជ្ញាបានពិពណ៌នាអំពីការចោទប្រកាន់ថាជា "ការលើកឡើងដដែលនូវសំណើលើកមុនដែលត្រូវបានច្រានចោលទាំងក្នុងពេលសវនាការ និងការប្តឹងសារទុក" ។

ក្នុងសេចក្តីសម្រេចវិនិច្ឆ័យការរបស់ខ្លួនលើសំណើដ៏សំខាន់នោះ អង្គជំនុំជម្រះសាលាដំបូង បានយល់ស្របជាមួយព្រះរាជអាជ្ញាថា តាមពិតសំណើសុំរបស់ នួន ជា នេះ គឺជាសំណើសុំច្រំដែលត្រួតគ្នាស្ទើរតែទាំងស្រុងជាមួយសំណើមុនៗដែល នួន ជា ធ្លាប់បានដាក់នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង និងដែលត្រូវបានអង្គជំនុំជម្រះសាលាដំបូង និងអងជំនុំជម្រះតុលាការកំពូលបានបដិសេធចោល ។ អង្គជំនុំជម្រះសាលាដំបូង បានរកឃើញថាសំណើសុំនាពេលបច្ចុប្បន្នត្រូវបានដាក់ដដែលថ្វីបើអង្គជំនុំជម្រះ ធ្លាប់បានបញ្ជាក់ម្តងហើយម្តងទៀតថា ការដាក់ឯកសារច្រំដែល អាចប៉ះពាល់ដល់សិទ្ធិរបស់ជនជាប់ចោទ ក្នុងការទទួលបានការជំនុំជម្រះដោយឆាប់រហ័សហើយអាចបណ្តាលឲ្យមានការដាក់ទណ្ឌកម្ម ។ ជាងនេះទៅទៀត អង្គជំនុំជម្រះសាលាដំបូងបានរកឃើញថា ការលើកឡើងរបស់ក្រុមមេធាវីការពារក់ ដែលថាចៅក្រមអង្គជំនុំជម្រះសាលាដំបូងមិនបានធ្វើការដោយឯករាជ្យដោយសារតែមានការចង្អុលបង្ហាញរបស់រដ្ឋាភិបាលនោះ គឺជាការប្រមាថមាក់ងាយ ការរើសអើង និងនាំឲ្យមានការដាក់ទោណ្ឌកម្ម ដោយមិនចាំបាច់យោងទៅលើសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង ឬក៏ផ្នែកណាមួយនៃកំណត់ត្រាសវនាការ ។

ទោះបីជាអង្គជំនុំជម្រះសាលាដំបូង លើកឡើងថា បណ្តឹងនោះគឺជាការមិនត្រឹមត្រូវ ក៏សេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងទទួលយកយ៉ាងច្បាស់លាស់ថា មានហេតុផលជាច្រើនក្នុងការបញ្ជាក់ថា ការជ្រៀតជ្រែកក្នុងប្រព័ន្ធយុត្តិធម៌ប្រហែលជាកើតឡើង ។ យោងតាមសេចក្តីសម្រេចរបស់អង្គជំនុំជម្រះតុលាការកំពូល "អនុលោមតាមវិធាន៣៥ អង្គជំនុំជម្រះដែលទទួលបាន

សំណើត្រូវពិនិត្យទៅលើការចោទប្រកាន់ ត្រូវវាយតម្លៃលើបញ្ហាថាតើជាអប្បបរមា មានសំអាង ដែលអាចជឿទេបានថា អំពើណាមួយដែលបានចែងក្នុងវិធាន ៣៥(១) នៃវិធានផ្ទៃក្នុងអាចត្រូវបាន ប្រព្រឹត្តឡើង និងត្រូវសម្រេចធ្វើសកម្មភាពសមស្រប ប្រសិនបើមាន ដោយអនុលោមតាមវិធាន ៣៥(២) នៃវិធានផ្ទៃក្នុង ។ ទោះបីជាយ៉ាងនេះក៏ដោយ តាមសេចក្តីសម្រេចរបស់ខ្លួន អង្គជំនុំជម្រះសាលាដំបូង មិនបានអនុវត្តបទដ្ឋាននៃការបង្ហាញភស្តុតាងនៃវិធាន៣៥(១) នៃវិធានផ្ទៃក្នុងលើការចោទប្រកាន់របស់លោក កាសស្ព័រ អានសាមេត នោះឡើយ ថ្វីបើកាលពិតដែលថាមិនមានសេចក្តីសម្រេចណាមួយពីមុន ដោះស្រាយលើបញ្ហានោះ ។ ផ្ទុយទៅវិញ អង្គជំនុំជម្រះផ្តោតទាំងស្រុងលើវិធាន៣៥(២) នៃវិធានផ្ទៃក្នុងដែល "ចែងអំពីមធ្យោបាយផ្នែកនីតិវិធី ដែលបើកផ្លូវឲ្យអង្គជំនុំជម្រះកំណត់នៅពេលដែលមានមូលហេតុណាមួយ ដែលអាចជឿជាក់ថា បុគ្គលមួយបានប្រព្រឹត្តការជ្រៀតជ្រែកក្នុងកិច្ចការរដ្ឋបាលតុលាការ" ។ ប្រសិនបើមិនមានមូលហេតុដែលអាចជឿជាក់បាននោះ មិនចាំបាច់កំណត់នូវការទទួលខុសត្រូវនោះឡើយ ។

ក្នុងការពិចារណាលើ "សំណើសុំឲ្យមានវិធានការ" អង្គជំនុំជម្រះ កត់សំគាល់ថា ការផ្អាកនីតិវិធីពុំមានលក្ខណៈសមស្របក្នុងកាលៈទេសៈនោះទេ ប្រសិនបើជនជាប់ចោទពុំបានចង្អុលបង្ហាញអំពីផលប៉ះពាល់ជាក់ស្តែងណាមួយអំពីការចោទប្រកាន់លើការជំនុំជម្រះដែលកំពុងប្រព្រឹត្តទៅ ឬពុំបានបង្ហាញថាជាសំណើដាច់ខាតនៃការផ្អាកកិច្ចដំណើការនីតិវិធី និងជាមធ្យោបាយតែមួយគត់របស់អង្គជំនុំជម្រះដើម្បីចាត់វិធានការទៅលើការរំលោភណាមួយ ដែលត្រូវបានគេជឿថាមានទៅលើសិទ្ធិរបស់ជនជាប់ចោទនោះឡើយ ។ ទាក់ទងទៅនឹងការលើកឡើងរបស់ចៅក្រម កាសស្ព័រ អានសាមេត ក្នុងសំណុំរឿង ០០៤ ដែលបញ្ជាក់ថា "បុគ្គលិករបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាបានជ្រៀតជ្រែកកងការស៊ើបអង្កេតសំណុំរឿង០០៤" ។ អង្គជំនជម្រះបញ្ជាក់អំពីឆន្ទានុសិទ្ធិរបស់ខ្លួនក្រោមវិធាន៣៥(២) នៃវិធានផ្ទៃក្នុងថាខ្លួនសម្រេចចិត្តមិនធ្វើការស៊ើបអង្កេតដោយមូលហេតុភាពប្រសិទ្ធភាព ហើយកត់សំគាល់ថា ការជំនុំជម្រះដោយយុត្តិធម៌ និងដោយសាធារណៈគឺជាដំណើរការសមស្រប សម្រាប់វិការៈនៃនីតិវិធីក្នុងការស៊ើបអង្កេត ។

គួរឲ្យកត់សំគាល់ សហចៅក្រមស៊ើបអង្កេតអន្តរជាតិថ្មីលោក មាក ហាមុន បានជំនួសចៅក្រម កាសស្ព័រ អានសាមេត ហើយត្រូវបានជឿថានឹងធ្វើការស៊ើបអង្កេតសំណុំរឿង០០៣ និង០០៤ ទោះបីជាមេធាវីការពារក្តីមិនទាន់ត្រូវបានតែងតាំងសម្រាប់ការការពារក្តីឲ្យជនសង្ស័យក៏ដោយ ក៏ជនសង្ស័យ១រូបក្នុងចំណោម៥រូប ក៏អាចសន្និដ្ឋានបានថា មេធាវីរបស់ជនសង្ស័យទាំងនោះនឹងលើកឡើងពីការចោទប្រកាន់របស់ចៅក្រម កាសស្ព័រ អានសាមេត នៅចំពោះមុខសហចៅក្រមស៊ើបអង្កេត និងអង្គបុរេជំនុំជម្រះ ។

បន្ទាប់ពីការស្នើសុំរបស់មេធាវីការពារក្តីរបស់ នួន ជា ចំពោះសាក្សីទាំង៦រូបខាងរដ្ឋាភិបាល អង្គជំនុំជម្រះសាលាដំបូងកត់សំគាល់ថា ការកំណត់សាក្សីបន្ថែមដែលនឹងត្រូវយកមកពិភាក្សានៅសវនការ នៅមិនទាន់យកមកជំនុំជម្រះនៅឡើយ និងស្ថិតក្រោមការពិនិត្យមើលរបស់អង្គជំនុំជម្រះក្នុងខណៈពេលដែលការជំនុំជម្រះក្នុងសំណុំរឿង០០២/០១នៅកំពុងដំណើរការ ។ ដូច្នេះហើយ គួរតែមានការរំពឹងទុកលើកិច្ចខិតខំប្រឹងប្រែងបន្ថែមរបស់មេធាវីការពារក្តីរបស់ នួន ជា ដើម្បីធានាឲ្យមាន ការផ្តល់សន្តិសុខលើការផ្តល់សក្ខីកម្ម ។